វិទ្យាល័យ ព្រែកលៀប
PREK LEAP HIGH SCHOOL

# ព្រឹត្តិបត្រព័ត៌មាន

## សាលារៀនជំនាន់ថ្មី វិទ្យាល័យ ព្រែកលៀប

ខែធ្នូ

លេខទូរស័ព្ទ៖ 015 431 400 / 089 322 400 / 031 537 4400
គេហទំព័រហ្វេប៊ុក៖ សាលារៀនជំនាន់ថ្មី វិទ្យាល័យ ព្រែកលៀប
អ៊ីមែល៖ prekleaphighschool@gmail.com
គេហទំព័រ៖ www.pl.ngs.edu.kh

## មាតិកា


- និតិវិធីនៃការជ្រើសរើសសិស្សចូលរៀនឆ្នាំសិក្សា ២០២៣-២០២៤........................................ ០១
- ពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០២៣-២០២៤ ........................................................... ០២
- ពិធីបើកបវេសនកាលឆ្នាំសិក្សា ២០២៣-២០២៤ ជានិមិត្តរូប នៅវិទ្យាល័យឧដុង្គ.......................... ០៣
- កម្មវិធីប្រកួតប្រជែងស្នាដៃយុវជនសតវត្សរ៍ទី21 ក្រោមប្រធានបទ STEM និងការផលិតអាហារ...........០៤
- កម្មវិធីសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រែកលៀបបានបញ្ចូលសមាធិក្នុងចិត្តសិក្សាទៅក្នុងកម្មវិធីសិក្សាប្រចាំថ្ងៃ...........................................................០៤
- សិស្សានុសិស្សក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀបចូលរួមប្រកួតការបង្ហោះខ្លែងក្នុងពិធីបុណ្យសមុទ្រលើកទី១០ នៅខេត្តកែប...............០៥
- យុវសិស្ស ឯកខឹម ចន្ទនន្ទតារាពិទូ ថ្នាក់ទី 12P1 ទទួលបានឱកាសអាហារូបករណ៍ថ្នាក់បរិញ្ញាបត្ររងទៅសិក្សានៅប្រទេសថៃ.................................០៦
- CLEEN 2023_Public Speaking Competition .. ...................................................................០៦
- សកម្មភាពប្រជុំ PLC លើប្រធានបទ ភាពផ្សេងគ្នារវាងគោលវិធីបង្រៀន វិធីសាស្ត្របង្រៀន និងល្បិចបង្រៀន ...................................................................០៧
- ការតម្រង់ទិសការប្រើប្រាស់ NGSPL Mobile App ដល់អាណាព្យាបាលសិស្សដែលទើបជាប់ថ្មីក្នុងកម្មវិធីសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រែកលៀប...........០៨
- ការចុះអនុស្សារណៈយោគយល់រវាងកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប និងសាលា Step Forward Abroad School .........................០៨
- សិស្សានុសិស្សក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប ទទួលបានជ័យលាភីក្នុងកម្មវិធីប្រកួតប្រជែងគណិតវិទ្យាអង្គរ ២០២៣......................០៩


## និតិវិធីនៃការជ្រើសរើសសិស្សចូលរៀនឆ្នាំសិក្សា ២០២៣-២០២៤

កម្មវិធីសាលារៀនជំនាន់ថ្មី រៀបចំឡើងដើម្បីកសាងនូវបរិស្ថានសមស្របសម្រាប់ការសិក្សានាសតវត្សរ៍ទី២១ ដោយក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងការរៀបចំសិល្បៈនៃការរៀបចំថ្នាក់រៀន បណ្ណាល័យថ្មីជាមួយនឹងធនធានលើបណ្ដាញ Internet។ ការផ្ដល់សេវាបច្ចេកវិទ្យា និងវិទ្យាសាស្ត្របន្ទប់ពិសោធយ៉ាងទូលំទូលាយ រួមជាមួយនឹងបច្ចេកទេសក្នុងការបង្រៀន ដែលមានភាពច្នៃប្រឌិតខ្ពស់។ កម្មវិធីនេះសង្ឃឹមថានឹងអាចជួយយុវជនកម្ពុជាក្នុងការអភិវឌ្ឍសមត្ថភាពមានគំនិតច្នៃប្រឌិត និងការគិតបែបស៊ីជម្រៅ អាចចូលរួមក្នុងការប្រកួតប្រជែងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។



(សកម្មភាពសិស្សានុសិស្សកំពុងប្រឡង)

នៅឆ្នាំសិក្សាថ្មី ២០២៣-២០២៤ នេះកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យ ព្រែកលៀប បានផ្សព្វផ្សាយដំណឹងដល់មាតា បិតា អាណាព្យាបាលសិស្ស ស្ដីពីការជ្រើសរើសសិស្សឱ្យចូលរៀនចាប់ពីកម្រិតថ្នាក់ទី៧ ដល់ថ្នាក់ទី១២។

ការបើកដំណើរការចុះឈ្មោះសុំធ្វើតេស្តចូលរៀនបានប្រព្រឹត្តទៅតាមរយៈតំណភ្ជាប់ Google Forms ចាប់ពីថ្ងៃទី០៤ ដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៣។ ដំណើរការនៃការប្រឡងបានធ្វើឡើងនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ តាមរយៈការធ្វើតេស្តសមត្ថភាពដោយអនុវត្តតាមកម្មវិធីដូចខាងក្រោម ៖

| កម្រិតថ្នាក់ | មុខវិជ្ជាប្រឡង |
|---|---|
| ថ្នាក់ទី៧ | ភាសាខ្មែរ និងគណិតវិទ្យា |
| ថ្នាក់ទី៨<br>ថ្នាក់ទី៩ | ភាសាខ្មែរ<br>គណិតវិទ្យា<br>វិទ្យាសាស្ត្រ (រូបវិទ្យា-គីមីវិទ្យា-ជីវវិទ្យា) |
| ថ្នាក់ទី១០<br>ថ្នាក់ទី១១ | ភាសាខ្មែរ<br>គណិតវិទ្យា<br>វិទ្យាសាស្ត្រ (រូបវិទ្យា-គីមីវិទ្យា-ជីវវិទ្យា) |

ក្រោយពីការប្រកាសលទ្ធផលនៃការធ្វើតេស្តចូលរៀនរួច អាណាព្យាបាល និងសិស្សានុសិស្សដែលបានធ្វើតេស្តជាប់ ត្រូវបានគណគ្រប់គ្រងអញ្ជើញមកប្រជុំដើម្បីទទួលការណែនាំស្ដីពីការដាក់ពាក្យចូលរៀន។

# ពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០២៣-២០២៤





*(សកម្មភាពក្នុងកម្មវិធីបើកបវេសនកាលនៅវិទ្យាល័យ ព្រែកលៀប ឆ្នាំសិក្សា២០២៣-២០២៤)*

នាព្រឹកថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៤ លោក សាំ ពិសិដ្ឋ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ បាន អញ្ជើញជាអធិបតីក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០២៣-២០២៤ នៅវិទ្យាល័យ ព្រែកលៀប ដោយមានការអញ្ជើញចូលរួមពីបុគ្គលិកអប់រំ គណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ អាជ្ញាធរ ថ្នាក់ស្រុក ឃុំ ភូមិ ព្រមទាំងអាណាព្យាបាលសិស្ស និងសិស្សានុសិស្សផងដែរ។



*(លោក សាំ ពិសិដ្ឋ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ)*

លោកប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនរាជធានី បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ លោកគ្រូ អ្នកគ្រូ បុគ្គលិកសិក្សា នៃវិទ្យាល័យ ព្រែកលៀប មាតាបិតា អាណាព្យាបាល និងសិស្សទាំងអស់ ដែលបានពុះពាររាល់ឧបសគ្គគ្រប់បែបយ៉ាងក្នុងការគាំទ្រ និងផ្ដល់នូវការបង្រៀន និងរៀន បានយ៉ាងល្អប្រសើរ ពីមួយឆ្នាំទៅមួយឆ្នាំ។




*(លោក ធុំ សុភក្តិ នាយកវិទ្យាល័យ ព្រែកលៀប ថ្លែងក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សា២០២៣-២០២៤)*

លោក ធុំ សុភក្តិ នាយកវិទ្យាល័យ ព្រែកលៀប បានថ្លែងនៅក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សា២០២៣-២០២៤ ដោយក្នុងនោះលោកបានបង្ហាញអំពីសមិទ្ធិផលមួយចំនួន ដែលសាលាសម្រេចបាន នាឆ្នាំសិក្សាកន្លងទៅ និងការដាក់ផែនការសម្រាប់ឆ្នាំសិក្សាថ្មីបន្ថែមទៀត។

ជាកិច្ចបញ្ចប់នៃពិធីបើកបវេសនកាលក្នុងឆ្នាំសិក្សាថ្មីនេះ លោកនាយកវិទ្យាល័យ ព្រែកលៀប ក៏បានជូនលិខិតថ្លែងអំណរគុណដល់ លោក សាំ ពិសិដ្ឋ ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ដែលបានឧបត្ថម្ភរូបសំណាកលោកតាក្រមង៉ុយដល់វិទ្យាល័យ ព្រែកលៀប។ លើសពីនេះទៅទៀតក៏មានពិធីចែកវត្ថុអនុស្សាវរីយ៍ដល់លោកគ្រូអ្នកគ្រូ និងសិស្សពូកែដែលទទួលបានចំណាត់ថ្នាក់លេខ១ ដល់លេខ៣ ក្នុងឆ្នាំសិក្សាកន្លងទៅផងដែរ។




*(ពិធីចែកលិខិតថ្លែងអំណរគុណ និងប័ណ្ណសរសើរ)*

# ពិធីបើកបវេសនកាលឆ្នាំសិក្សា ២០២៣-២០២៤ ជានិមិត្តរូប នៅវិទ្យាល័យឧដុង្គ



*(លោក ឆុំ សុភក្តិ នាយកវិទ្យាល័យ ព្រែកលៀប ឡើងធ្វើបទបង្ហាញស្តីពីកម្មវិធីសាលារៀនជំនាន់ថ្មី)*

លោកនាយក និងលោកគ្រូអ្នកគ្រូក្នុងកម្មវិធីសាលារៀនជំនាន់ថ្មីនៃវិទ្យាល័យព្រែកលៀបបានដឹកនាំសិស្សានុ-សិស្សចូលរួមការតាំងពិព័រណ៍ស្នាដៃ និងធ្វើបទបង្ហាញដោយលោកនាយកផ្ទាល់ដោយលោកនាយកស្តីពីការដំណើរការគ្រប់គ្រងកម្មវិធីសាលារៀនជំនាន់ថ្មី ក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សា ២០២៣-២០២៤ នៅវិទ្យាល័យឧដុង្គ ខេត្តកំពង់ស្ពឺក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងមានវត្តមាន ឯកឧត្តម ពេជ សោភ័ន ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ឯកឧត្តម វ៉ី សំណាង អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សជាច្រើនរូប។

ដើម្បីសម្រេចបានទិសដៅការងារដូចបានរៀបរាប់ខាងលើ ជាពិសេសក្នុងឆ្នាំសិក្សាថ្មីនេះ ឯកឧត្តមបណ្ឌិតសភាចារ្យ ស្នើឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ចូលរួមយ៉ាងសកម្មពេញទំហឹងអនុវត្តតួនាទី និងភារកិច្ច រៀងខ្លួនៗប្រកបដោយ ប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចបាននូវគោលដៅ អប់រំជាតិ ជាពិសេសការសម្រេចបានសាលារៀនគំរូ និងចូលរួមអនុវត្តយុទ្ធនាការសាលារៀន ស្អាត គ្មានសំរាម និងស្នើស្ថាប័នអង្គភាពពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ សូមចូលរួមគាំទ្រ និង អភិវឌ្ឍវិស័យអប់រំកម្ពុជា រួមទាំងលោកឪពុក អ្នកម្តាយ និងអ្នកអាណាព្យាបាលទាំងអស់ នៅទូទាំងប្រទេស សូមចូលរួមចំណែកឱ្យសកម្មខ្លាំងក្លា ដល់ការជួយអប់រំកូនចៅរបស់ខ្លួន។

សូមជម្រាបថា ក្នុងកម្មវិធីបើកបវេសនកាលនិមិត្តរូបនេះក៏មានពិធីប្រគល់សម្ភារៈសិក្សា សម្ភារៈកីឡា ការពិព័រណ៍ស្នាដៃសិស្សសាលារៀនជំនាន់ថ្មី និងវិទ្យាល័យធនធានការអនុវត្តវិធីសាស្ត្របង្រៀនថ្មី ការធ្វើបទបង្ហាញការធ្វើពិសោធន៍មុខវិជ្ជានានា ពិសេសគឺការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្តង់ដាសាលារៀនគំរូ៕











*(សកម្មភាពក្នុងកម្មវិធីបើកបវេសនកាលនៅវិទ្យាល័យឧដុង្គ ឆ្នាំសិក្សា២០២៣-២០២៤)*

# កម្មវិធីប្រកួតប្រជែងស្នាដៃយុវជនសតវត្សរ៍ទី២១ក្រោមប្រធានបទ STEM និងការផលិតអាហារ

សៀមរាប៖ នាយកដ្ឋានយុវជន នៃអគ្គនាយកដ្ឋានយុវជន ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំពិធីបិទ កម្មវិធីប្រកួតប្រជែងស្នាដៃយុវជនសតវត្សរ៍ទី២១ ក្រោមប្រធានបទ «STEM និងការផលិតអាហារ» ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ស៊ាន បូរ៉ាត រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា ដោយមានការចូលរួមពីប្រតិភូយុវជនអញ្ជើញមកពីទូទាំង២៥រាជធានី ខេត្ត។




គួបញ្ជាក់ថា ឆ្លងកាត់ការប្រកួតប្រជែងស្នាដៃយុវជនសតវត្សរ៍ទី២១ ទាំង២៥ រាជធានី ខេត្ត លើការតាំងពិពណ៌បង្ហាញគម្រោង និងការធ្វើបទបង្ហាញ រយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី៣០ វិច្ឆិកា ដល់ថ្ងៃទី០២ ខែធ្នូឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលជាតិយុវជនកម្ពុជា ខេត្តសៀមរាប។ ក្នុងនោះ សិស្សសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រែកលៀប ក្រុម never give up ដែលតំណាងរាជធានីភ្នំពេញ បានដាក់តាំងបង្ហាញស្នាដៃស្រាវជ្រាវលើគម្រោង Digital Aquaponics នេះផងដែរ។







# កម្មវិធីសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រែកលៀបបានបញ្ចូលសមាធិក្នុងចិត្តសិក្សាទៅក្នុងកម្មវិធីសិក្សាប្រចាំថ្ងៃ









បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអប់រំចិត្តសម្រាប់គណៈនាយក លោកគ្រូអ្នកគ្រូ និងសិស្សរួចមក លោកគ្រូអ្នកគ្រូបានយកមកអនុវត្តនៅតាមថ្នាក់រៀននៃម៉ោងទីមួយជារៀងរាល់ថ្ងៃ។

គួបញ្ជាក់ផងដែរថា ចិត្តវិទ្យា (ចិត្តវិជ្ជា ក្នុងវចនានុក្រមខ្មែរ) គឺជាវិទ្យាសាស្ត្រដែលសិក្សាអំពីចិត្ត អារម្មណ៍ សតិ (គំនិត) របស់មនុស្សដែលមានទំនាក់ទំនងទៅនឹងការលូតលាស់ ការផ្លាស់ប្តូរនៃ ចរិយា អត្តចរិត ឥរិយាបថ បុគ្គលិកលក្ខណៈ ព្រមទាំងសិក្សាជម្ងឺខាងផ្លូវចិត្ត (ចិត្តមិនប្រក្រតី)ផ្សេងៗ។ គោលបំណងនៃចិត្តវិទ្យាគឺដើម្បីស្វែងយល់អោយច្បាស់លាស់នូវចិត្ត និង ឥរិយាបថរបស់មនុស្ស ក៏ដូចជាទំនាក់ទំនងរវាងមនុស្សទាំងនោះក្នុងក្រុម ដោយការពិសោធ និង វិធីផ្សេងៗតាមបែបវិទ្យាសាស្ត្រ។ អ្នកដែលសិក្សាចិត្តវិទ្យា ត្រូវបានអោយឈ្មោះថា អ្នកចិត្តវិទ្យា ឬ ចិត្តវិទូ ។ ចិត្តវិទូសិក្សាស្វែងយល់នូវគំនិតដូចជា ប្រត្យាអារម្មណ៍ (Perception) ញាណ (Cognition) បម្រុងប្រយ័ត្ន (Attention) អារម្មណ៍(Emotion) មុខងារនៃខួរក្បាល (Brain Functioning) បុគ្គលិកលក្ខណៈ (Personality) ឥរិយាបថ(Behavior) និង ទំនាក់ទំនងក្នុងចិត្តមនុស្សផ្សេងទៀត ត។

# សិស្សានុសិស្សក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀបចូលរួមប្រកួតការបង្ហោះខ្លែងក្នុងពិធីបុណ្យសមុទ្រលើកទី១០ នៅខេត្តកែប







កម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀបក៏មានវត្តមានក្នុងពិធីបុណ្យសមុទ្រលើកទី១០ នៅខេត្តកែបផងដែរ។ សិស្សានុសិស្សក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀបបានរៀបចំនាំយកខ្លែងទៅចូលរួមប្រកួតផងដែរនៅថ្ងៃទី០២ និងទី០៣ ខែធ្នូ ឆ្នាំ២០២៣ នៅតំបន់ស្នួនខ្លែងជ្រោយសមុទ្រ។ កម្មវិធីប្រកួតខ្លែងបានប្រព្រឹតទៅក្រោមអធិបតីភាព ឯកឧត្តម សុខ សូកេន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មការអន្តរក្រសួងរៀបចំពិធីបុណ្យសមុទ្រ និងលោកជំទាវផ្តល់កិត្តិយសក្នុងការប្រគល់ពានរង្វាន់ក្នុងកម្មវិធីប្រកួតខ្លែងដែលរៀបចំដោយសហភាពសហព័ន្ធយុវជនកម្ពុជា សហការណ៍ជាមួយ មជ្ឈមណ្ឌលសម្រាប់ការអប់រំ និងសិក្សាពីចម្ងាយ ដើម្បីអបអរសាទរពិធីបុណ្យសមុទ្រលើកទី១០ ជុំទី៣ នាខេត្តកែប ដោយកម្មវិធីប្រកួតនេះគណៈកម្មការដាក់ពន្ទុទៅលើ សោភណ្ឌភាព រយៈកម្ពស់ និង ថេរៈវេលា។ សិស្សានុសិស្សក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀបទទួលបានចំណាត់ថ្នាក់លេខ២ និងលេខ៥។

គួរជម្រាបថា ការរៀបចំពិធីបុណ្យសមុទ្រមានគោលបំណងនៃពិធិបុណ្យសមុទ្រ គឺដើម្បីរួមគ្នាអភិរក្សការពារធនធានធម្មជាតិសមុទ្រ និងថែរក្សាបរិស្ថានឆ្នេរឲ្យបានស្អាត ដើម្បីបម្រើដល់ការអភិវឌ្ឍទេសចរណ៍ប្រកដោយចិរភាព និងការទទួលខុសត្រូវ ព្រមទាំងលើកតម្កើងការផ្សព្វផ្សាយគោលដៅទេសចរណ៍តំបន់ឆ្នេរកម្ពុជា ឱ្យកាន់តែទូលំទូលាយទាក់ទាញទេសចរជាតិនិងអន្តរជាតិមកទស្សនាកាន់តែច្រើន។

ពិធីបុណ្យសមុទ្រត្រូវបានធ្វើឡើង៩លើករួចមកហើយ នៅតាមខេត្តទាំង៤ដែលជាប់សមុទ្រកម្ពុជា ហើយលើកទី១០ នៅខេត្តកែបនេះ ធ្វើឡើងក្រោមប្រធានបទ «ទាំងអស់គ្នាដើម្បីទេសចរណ៍»។














# យុវសិស្ស ឯកខឹម ចន្ទខន្តីតារាពិទូ ថ្នាក់ទី 12P1 ទទួលបានឱកាសអាហាររូបករណ៍ថ្នាក់បរិញ្ញាបត្ររង ទៅសិក្សានៅប្រទេសថៃ

អបអរសាទរយុវសិស្ស ឯកខឹម ចន្ទខន្តីតារាពិទូ ថ្នាក់ទី 12P1 ទទួលបានឱកាសអាហាររូបករណ៍ថ្នាក់បរិញ្ញាបត្ររង ទៅសិក្សានៅប្រទេសថៃ វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស IRPC ។

គួរបញ្ជាក់ផងដែរថា វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស IRPC គឺជាវិទ្យាស្ថានមួយដែលឈានមុខគេមួយនៅក្នុងប្រទេសថៃ បានផ្តល់នូវ អាហាររូបករណ៍ទៅកាន់ប្រទេសជាច្រើនដូចជា កម្ពុជា ថៃ ឡាវ វៀតណាម មីយ៉ាន់ម៉ា។ លក្ខខណ្ឌជ្រើសរើសសម្រាប់សិស្សានុសិស្សនៃព្រះរាជាណាចក្រកម្ពុជាដែលមានបំណងចង់បន្តការសិក្សា កម្រិតវប្បធម៌ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

ថ្នាក់បរិញ្ញាបត្ររង នៅក្នុងប្រទេសថៃ។

អត្ថប្រយោជន៍ទទួលបាន

- ថ្លៃសិក្សា ១០០%
- ប្រាក់ឧបត្ថម្ភ
- កន្លែងស្នាក់នៅ
- ការធានារ៉ាប់រង
- និង អត្ថប្រយោជន៍ផ្សេងៗ




# CLEEN 2023_Public Speaking Competition





Congratulations to the winners of CPC 2023!!

We have finally found the winners of CLEEN 2023 Public Speaking Competition. We are very happy to see the personal development of each candidate today. Today, we witnessed amazing speeches from our 5 finalists.

With accurate and precise judgment from our judges, we are proud to announce the winners as follows:

1st place: Pheang Sreylen

2nd place: Bunna Chamrong

3rd place: Kong Sievmey & Kong Leakhena

4th place: Heng Chanpanha

5th place: Suy Kanika & Tat Ritheanor

We would like to express our gratitude to our school principals especially our guest of honor, Mrs. Vao Samoun, Vice Principal of NGSPL for showing support to our competition and the team as a whole. Thanks to our excellent and professional judges Mr. Khim Makara, Mr. Sok Sophearith and Mr. Chea Phearum for your time and effort to give insightful feedback and comments to our speakers.

Last but not least, we thank everyone in the team, sponsors, teachers, participants and all guests for taking your precious time to make our competition a success.

Once again, congratulations everyone!! You are all the winners!

# សកម្មភាពប្រជុំ PLC លើប្រធានបទ ភាពផ្សេងគ្នារវាង គោលវិធីបង្រៀន វិធីសាស្រ្ត បង្រៀន និងល្បិចបង្រៀន

នៅរសៀល ថ្ងៃព្រហស្បតិ៍ ពីរកើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ពុទ្ធស័ករាជ ពីរពាន់ប្រាំរយហុកសិបប្រាំពីរ ត្រូវនឹងថ្ងៃទីដប់បួន ខែធ្នូ ឆ្នាំពីរពាន់ម្ភៃបី វេលាម៉ោងបីរសៀលមានការបើកអង្គប្រជុំរួមនៅសាលប្រជុំជំនាន់ថ្មីនៃវិទ្យាល័យព្រែកលៀប។

សមាសភាពអញ្ជើញចូលរួមៈ

១. គណៈនាយកវិទ្យាល័យព្រែកលៀប

២. លោកគ្រូ/អ្នកគ្រូជាបុគ្គលិករដ្ឋបាល ហិរញ្ញវត្ថុ បណ្ណារក្ស ប្រឹក្សាគរុកោសល្យ នៃកម្មវិធីសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រែកលៀបទាំងអស់

របៀបវារៈនៃអង្គប្រជុំ

១.ក្នុងរបៀបវារៈទីមួយអ្នកគ្រូ ចេង ភារីបានធ្វើបទបង្ហាញពីគោលវិធី វិធីសាស្រ្ត និងល្បិចក្នុងការបង្រៀន

២.ផ្សេងៗ

ខ្លឹមសារនៃអង្គប្រជុំ

ក្នុងរបៀបវារៈទីមួយអ្នកគ្រូ ចេង ភារី បានចាប់ផ្ដើមលេងហ្គេម Hot Potato ដើម្បីឱ្យលោកគ្រូ អ្នកគ្រូចែករំលែកអ្វីទៅដែលហៅថាគោលវិធី វិធីសាស្រ្ត និងល្បិច។ បន្ទាប់មកអ្នកគ្រូ ចេង ភារី បាន ផ្តល់និយមន័យគោលវិធីដែលសំដៅលទ្រឹស្តីលើឧទាហរណ៍មាន គ្រូមជ្ឈមណ្ឌល សិស្សមជ្ឈមណ្ឌលជាដើម។ចំណែកវិធីសាស្រ្តមានជំហានច្បាស់លាស់ដូចជា IBL ដែលគាំទ្រគោលវិធី។ ល្បិចសំដៅលើបច្ចេកដែលគាំទ្រដល់វិធីសាស្រ្ត។ បន្ទាប់មកអ្នកគ្រូ គិត សុគន្ធី និងអ្នកគ្រូ ម៉េង រិទ្ធិកាបានលើកយកល្បិចក្នុងការបង្រៀន JISAW1 និង JISAW 2 ដោយបបានប្រើ Pickerwheel ដើម្បីជ្រើសរើសគ្រូចូលក្រុម។

ក្នុងរបៀវារៈទីពី លោកនាយកបានលើកឡើងថាដោយសារតែប៉ុន្មានថ្ងៃនេះលោកគ្រូ អ្នកគ្រូមួយចំនួនបានថតរូបភាពនៃសកម្មភាពរៀន និងបង្រៀនក្នុងថ្នាក់ដោយភ្ជាប់មកជាមួយចំណងជើងដែលមិនស្របជាមួយសកម្មភាពនៅក្នុងរូបភាព។ បន្ថែមពីនេះទៀតលោកគ្រូ អ្នកគ្រូមួយចំនួនមិនទាន់ចេះថតរូបឱ្យមើលទៅស្អាតដូចឆ្នេះលោកនាយកបានស្នើលោក សោ មុនីរតនៈ ធ្វើបទបង្ហាញដល់លោកគ្រូ អ្នកគ្រូពីរបៀបថតរូបដល់លោកគ្រូ អ្នកគ្រូ។ លោកនាយកក៏បានស្នើរលោកគ្រូ អ្នកគ្រូទាំងអស់ផ្ញើរូបភាពនៃសកម្មភាពរៀន និង បង្រៀនចូលក្នុងក្រុមតេឡេក្រាមជាប្រចាំ។ លោកស្រីនាយិការងបានស្នើរឱ្យលោកគ្រូ អ្នកគ្រូដែលមិនគ្រប់ម៉ោងទទួលយកកាលវិភាគប្រចាំការនិងចុះហត្ថលេខាលើសៀវភៅសិក្ខាវិទ្ធ។បន្ទាប់មកលោកនាយករងបានអានលិខិតបង្គាប់ការដល់បុគ្គលិកបន្ថែមលើការងាររៀននិងបង្រៀនដើម្បីពង្រឹងសណ្តាប់ធ្នាប់ក្នុងសាលារៀន។

អង្គប្រជុំត្រូវបានបញ្ចប់នៅរសៀលថ្ងៃព្រហស្បតិ៍ ពីរកើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ពុទ្ធស័ករាជ ពីរពាន់ប្រាំរយហុកសិបប្រាំពីរ ត្រូវនឹងថ្ងៃទីដប់បួន ខែធ្នូ ឆ្នាំពីរពាន់ម្ភៃបី វេលាម៉ោងប្រាំល្ងាចប្រកបដោយបរិយាកាសដ៏រីករាយ











## ការតម្រង់ទិសការប្រើប្រាស់ NGSPL Mobile App ដល់អាណាព្យាបាលសិស្សដែលទើបជាប់ថ្មីក្នុងកម្មវិធីសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រែកលៀប





ជារៀងរាល់ដើមឆ្នាំសិក្សា កម្មវិធីសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រែកលៀបតែងតែបង្កើតនូវកម្មវិធីជួបជាមួយមាតាបិតាសិស្សានុសិស្សដើម្បីធ្វើការតម្រង់ទិសស្តីពីការប្រើប្រាស់កម្មវិធី NGSPL Mobile App។ ការប្រើប្រាស់កម្មវិធី NGSPL Mobile App មានគោលបំណង់ជួយដល់មាតាបិតាអាណាព្យាបាលសិស្សក្នុងការតាមដានការសិក្សារបស់កូនពួកគាត់ លើសពីនេះទៅទៀតកម្មវិធីនេះ ក៏ជួយសម្រួលដល់ការសុំច្បាប់ផងដែរ ដោយមិនតម្រូវឱ្យមាតាបិតា អាណាព្យាបាលសិស្សមកសុំច្បាប់ដោយផ្ទាល់នោះទេ គឺគ្រាត់តែធ្វើការស្នើសុំក្នុងកម្មវិធីជាការស្រេច។

## ការចុះអនុស្សារណៈយោគយល់រវាងកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប និងសាលា Step Forward Abroad School



នៅថ្ងៃច័ន្ទ ទី១៨ ខែធ្នូ ឆ្នាំ២០២៣ នៅសាលប្រជុំជំនាន់ថ្មី នៃវិទ្យាល័យព្រែកលៀប បានរៀបចំផ្សព្វផ្សាយអំពីការដាក់អាហារូបករណ៍ ដល់សិស្សានុសិស្សក្នុងសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រែកលៀប ដែលមានបំណងបន្តការសិក្សានៅប្រទេសចិន និងឱកាសទទួលបានការផ្លាស់ប្តូរនូវបទពិសោធ បច្ចេកទេស ទស្សនកិច្ចសិក្សា និងអត្ថប្រយោជន៍ផ្សេងៗ រៀបចំដោយ Step Forward Abroad School។

សាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប (New Generation School Prek Leap High School) មានទីតាំងនៅ ផ្លូវជាតិលេខ 6A សង្កាត់ ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ តំណាងដោយ លោកនាយក អ៊ុំ សុភក្តិ និងសាលាបណ្តុះបណ្តាល ស្ទេប ហ្វរវើដ អឺបដ ស្គូល (Step Forward Abroad School ) មានទីស្នាក់ការ នៅអគារលេខ 87 ផ្លូវលេខ 155 សង្កាត់ទួលទំពូងទីមួយ ខណ្ឌចំការមន រាជធានីភ្នំពេញ តំណាងដោយលោក លឹម វុទ្ធី ។

ស្ថាប័នអប់រំទាំងពីរបានយោគយល់គាំទគ្នា សហការគ្នា ដូចខាងក្រោម៖

- ភាគីទាំងពីរឯកភាពគ្នាជម្រុញផែនការណ៍ចុះតម្រង់ទិសសិស្សមធ្យមសិក្សាក្រោមសិក្ខាសាលា ប្រធានបទ "ការ បណ្តុះក្តីស្រមៃទៅសិក្សានៅបរទេស" ។
- ភាគីទាំងពីរឯកភាពគ្នាជម្រុញគំនិតសិក្សានៅក្រៅប្រទេស ដល់សិស្សមធ្យមសិក្សា តាមរយៈឱកាសទទួលបានអា ហារូបករណ៍ ៥០កន្លែង ក្នុងមួយឆ្នាំ និងទស្សនកិច្ចសិក្សាទៅកាន់សាកលវិទ្យាល័យប្រទេសចិន។
- ភាគីទាំងពីរឯកភាព គាំទ្រគ្នា សហការគ្នាចាប់ពីថ្ងៃចុះហត្ថលេខានេះ រហូតដល់ ខែមករា ឆ្នាំ២០២៦។







# សិស្សានុសិស្សក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប ទទួលបានជ័យលាភីក្នុងកម្មវិធីប្រកួតប្រជែងគណិតវិទ្យាអង្គរ ២០២៣

ក្រោមកិច្ចសហការរវាងក្រសួងអប់រំ យុវជននិងកីឡា ជាមួយនឹងវិស័យឯកជនកម្មវិធីប្រឡងប្រជែងគណិតវិទ្យាអង្គរ ដ៏ធំប្រចាំប្រទេសកម្ពុជា AMC ( Angkor Mathematics Competition) ដែលមានសិស្សានុសិស្ស ចូលរួមប្រកួតប្រជែងជាង ៥ ០០០នាក់ មកពីជាង ៨០សាលារៀនទាំងរដ្ឋ និងឯកជនទូទាំងប្រទេស បានឈានដល់ការប្រកួតប្រជែងវគ្គផ្តាច់ព្រ័ត្រ និងរកឃើញជើងឯកហើយ ជាមួយនឹងការអបអរសាទរយ៉ាងខ្លាំង ពីសំណាក់អាណាព្យាបាលរបស់សិស្ស។

កម្មវិធីប្រឡងប្រជែងគណិតវិទ្យាអង្គរ ដ៏ធំប្រចាំប្រទេសកម្ពុជាវគ្គផ្តាច់ព្រ័ត្រនេះ បានធ្វើឡើងនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ នៅសាលមហោស្រពកោះពេជ្រ ដោយមានការចូលរួមពីបណ្តាក្រុមហ៊ុន អាព្យាបាល និងសិស្សានុសិស្ស រាប់ពាន់នាក់។ AMC ជាវេទិការប្រឡងប្រជែងគណិតវិទ្យា ផ្តល់ឱកាសឱ្យសិស្សានុសិស្សអាចវាស់ស្ទង់សមត្ថភាពគណិតវិទ្យា លើកកម្ពស់ការអប់រំផ្នែកវិទ្យាសាស្ត្រ ព្រមទាំងមានលើកកម្ពស់វិស័យអប់រំផងដែរ ហើយចំពោះសិស្សដែលអាចចូលរួមប្រកួតមានចាប់ពីថ្នាក់ទី៣ ដល់ថ្នាក់ទី១២ផងដែរ។

អបអរសាទរសិស្សានុសិស្សក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប ទទួលបានជ័យលាភី៖ មេដាយមាស 1 (TOP 6), មេដាយមាស 1, មេដាយប្រាក់ 5, មេដាយសំរិទ្ធិ 8 ក្នុងកម្មវិធីប្រកួតប្រជែងគណិតវិទ្យាអង្គរ ២០២៣ Angkor Mathematics Competition 2023។































វិទ្យាល័យ ព្រែកលៀប

PREK LEAP HIGH SCHOOL

## ព្រឹត្តិបត្រព័ត៌មានប្រចាំខែធ្នូ

### ទំនាក់ទំនង


| | |
|---|---|
| លេខទូរស័ព្ទ | ៖ 015 431 400 / 089 322 400 / 031 53 74 400 |
| អ៊ីមែល | ៖ prekleaphighschool@gmail.com |
| គេហទំព័រ | ៖ www.pl.ngs.edu.kh |
| គេហទំព័រហ្វេសប៊ុក | ៖ សាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប |
| អាសយដ្ឋាន | ៖ ផ្លូវជាតិលេខ៦ សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ |

*រៀបរៀងដោយ៖ លោកគ្រូ សោ មុនីរតនៈ*